សហព័ន្ធខ្មែរកម្ពុជាក្រោម
KHMERS KAMPUCHEA-KROM FEDERATION
Asia – Australia – Europe – North America.
A member of UNPO & IDBF

Office of President: P.O. Box 0193 •Pennsauken • NJ • 08110 •U.S.A . Tel: (856) 655-2117
http://www.khmerkrom.net • Email: thach.thach@khmerkrom.org

# លិខិតចូលរួមរំលែកទុក្ខ

## ជនរងគ្រោះដោយព្យុះកេតសាណា នៅកម្ពុជា

សហព័ន្ធខ្មែរកម្ពុជាក្រោម សូមចូលរួមរំលែកទុក្ខដល់ជនរួមឈាមខ្មែរ ដែលទទួលរងគ្រោះដោយ **ខ្យល់ព្យុះកេតសាណា** កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ នៅកម្ពុជា។

គ្រោះមហន្តរាយដោយធម្មជាតិ បានកើតឡើងជាហូរហែរ និងជាគ្រោះថ្នាក់មួយ ដែលមនុស្សជាតិមិនអាចឃាត់ឃាំង ឬទប់ស្កាត់មិនឲ្យឡើងបានឡើយ។

នាពេលបច្ចុប្បន្នពិភពលោក មានការព្រួយបារម្មណ៍លើការប្រែប្រួលអាកាសធាតុ នៃការឡើងកំដៅរបស់ពិភពលោក ហើយមានការចាប់អារម្មណ៍បំផុត នៅតំបន់អាស៊ីអាគ្នេយ៍ នៃប្រទេសកម្ពុជា និងកម្ពុជាក្រោម ដោយសារការរលាយទឹកកកនៅតំបន់ប៉ូលខាងជើងនិងខាងត្បូង។

មូលហេតុនេះទឹកជំនន់, ខ្យល់ព្យុះ និងកើតមានឡើង ដែលធ្វើឲ្យអ្នកវិទ្យាសាស្ត្រ រួមទាំងអ្នកដឹកនាំពិភពលោក បានយកចិត្តទុកដាក់លើបញ្ហានេះ។

សហព័ន្ធខ្មែរកម្ពុជាក្រោម មានការយកចិត្តទុកដាក់និងឃ្លាំមើលនូវចរន្ត **ព្យុះកេតសាណា** ចាប់ពីប្រទេសហ្វីលិភីន ដោយបារម្មណ៍ពីគ្រោះមហន្តរាយមកប្រទេសខ្មែរយើង។

អាស្រ័យហេតុនេះ សហព័ន្ធសូមអំពាវនាវដល់ជនរួមឈាមខ្មែរនៅជុំវិញពិភពលោក សូមមេត្តាយកចិត្តទុកដាក់ជួយសង្គ្រោះដល់ជនរួមឈាមខ្មែរយើង ដែលទទួលរងគ្រោះដោយមហន្តរាយនេះ តាមលទ្ធភាព និងសមត្ថភាពរបស់លោកអ្នក។

សហព័ន្ធខ្មែរកម្ពុជាក្រោម សូមចូលរួមរំលែកទុក្ខចំពោះជនរួមឈាម ដែលទទួលរងគ្រោះដោយខ្យល់ព្យុះកេតសាណា ឲ្យបានជៀសផុតនូវគ្រោះកាចទាំងឡាយដោយធម្មជាតិនោះ។

សូមមេត្តាទាក់ទងតាមសាខាសហព័ន្ធខ្មែរកម្ពុជាក្រោម នៅគ្រប់តំបន់ ចូលរួមវិភាគទានក្នុងមូលនិធិសង្គ្រោះដល់ជនរួមឈាមខ្មែរ ដោយខ្យល់ព្យុះកេតសាណា។

ធ្វើនៅសហរដ្ឋអាមេរិក, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៩

អំពីយើងខ្ញុំព្រះករុណាខ្ញុំបាទ

KHMERS KAMPUCHEA KROM FEDERATION PRESIDENT

**ថាច់ ង៉ុក ថាច់**

ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម